# ការជួញដូរ និងការរត់ពន្ធ

**ការជួញដូរមនុស្ស** គឺជា៖

- ការជួញញដូរផ្លូវភេទ ដែលពាណិជ្ជកម្មផ្លូវភេទនេះត្រូវបានធ្វើឡើងដោយបង្ខំ បោកបញ្ឆោត គម្រាមកំហែង ឬជនប្រព្រឹត្តផ្លូវភេទនេះ មានអាយុក្រោម ១៨ ឆ្នាំ ឬ
- ការជ្រើសរើសបុគ្គលិក, ការផ្តល់ទីជម្រក ការដឹកជញ្ជូន ការផ្តល់ ឬការទទួលយកមនុស្សឲ្យធ្វើការងារ ឬបម្រើសេវា ដោយប្រើកម្លាំង បោកបន្លំ ឬគម្រាមកំហែងសម្រាប់គោលបំណង ដែលជាកម្មវត្ថុនៃអំពើទាសភាពមិនស្ម័គ្រចិត្ត កេងប្រវ័ញ្ចដោះបំណុល ឬទាសករ។

**ការរត់ពន្ធមនុស្ស** គឺជាអំពើនាំចូលមនុស្សទៅក្នុងសហរដ្ឋអាមេរិកដោយមិនអនុវត្តតាមច្បាប់អន្តោប្រវេសន៍។ បទល្មើសនេះរួមមានទាំងការនាំសាច់ញាតិដោយខុសច្បាប់ចូលក្នុងសហរដ្ឋអាមេរិក ក៏ដូចជាការដឹកជញ្ជូនមនុស្សដោយខុសច្បាប់ និងការផ្តល់កន្លែងស្នាក់នៅដោយខុសច្បាប់ដល់សាច់ញាតិនៅក្នុងសហរដ្ឋអាមេរិក។

ពាក្យទាំងនេះមិនអាចប្តូរគ្នាបានទេ

- **ការរត់ពន្ធ**គឺជាការដឹកជញ្ជូនជាមូលដ្ឋាន
- **ការជួញដូរ**គឺការធ្វើអាជីវកម្មជាមូលដ្ឋាន

BLUE CAMPAIGN
One Voice. One Mission. End Human Trafficking.®

បើមានសកម្មភាពសង្ស័យសូមរាយការណ៍មក៖
**1-866-DHS-2-ICE** (1-866-347-2423)
**www.dhs.gov/bluecampaign**

## សន្ទស្សន៍នៃការជួញដូរមនុស្ស

- ❑ តើជនរងគ្រោះមានឯកសារសម្គាល់អត្តសញ្ញាណ និងឯកសារធ្វើដំណើរនៅជាប់នឹងខ្លួនឬទេ? បើឯកសារទាំងនេះមិននៅនឹងជនរងគ្រោះទេ តើនរណាជាអ្នកកាន់កាប់ឯកសារទាំងនេះ?
- ❑ តើជនរងគ្រោះត្រូវបានណែនាំឲ្យត្រូវនិយាយអ្វីខ្លះទៅមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីអន្តោប្រវេសន៍ឬទេ?
- ❑ តើប្រាក់បៀវត្សន៍របស់ជនរងគ្រោះត្រូវបានយកទៅបង់ថ្លៃរត់ពន្ធឬទេ? (ការបង់ថ្លៃរត់ពន្ធតែម្យ៉ាងមិនចាត់ទុកជាការជួញដូរទេ។)
- ❑ តើជនរងគ្រោះត្រូវបានបង្ខំឲ្យរួមភេទឬទេ?
- ❑ តើជនរងគ្រោះមានសេរីភាពដើរហើរឬទេ?
- ❑ តើជនរងគ្រោះ ឬគ្រួសាររបស់ជនរងគ្រោះ ធ្លាប់ត្រូវបានគម្រាមកំហែងបង្កគ្រោះថ្នាក់ទេ បើជនរងគ្រោះចង់រត់គេច?
- ❑ តើជនរងគ្រោះធ្លាប់ត្រូវបានគម្រាមបណ្តេញចេញ ឬចាត់វិធានការអនុវត្តច្បាប់ឬទេ?
- ❑ តើជនរងគ្រោះត្រូវបានរងគ្រោះ ឬត្រូវបានបង្អត់អាហារ ទឹក មិនឲ្យដេក គ្មានការថែទាំសុខភាព ឬតម្រូវការចាំបាច់សម្រាប់ជីវិតផ្សេងទៀតទេ?
- ❑ តើជនរងគ្រោះអាចទាក់ទងជាមួយមិត្តភ័ក្តិ និងគ្រួសារដោយសេរីឬទេ?
- ❑ តើជនរងគ្រោះជាកុមារមានពាក់ព័ន្ធនឹងពាណិជ្ជកម្មផ្លូវភេទឬទេ?
- ❑ តើជនរងគ្រោះត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសេវាកម្មសង្គម ឬសាសនាដែរឬទេ?

បើមានសកម្មភាពសង្ស័យសូមរាយការណ៍មក៖ **1-866-DHS-2-ICE** (1-866-347-2423)

**www.dhs.gov/bluecampaign**

BC-IC1-KHM 07/14